I- ទីស្តីការគណៈរដ្ឋមន្ត្រី

១- អនុក្រឹត្យ

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ១៩៩៤

អនុក្រឹត្យលេខ ២៨ អនក្រ

ស្តីពីការបង្កើតនាយកដ្ឋានសំភារៈបច្ចេកទេស

ចំណុះក្រសួងការពារជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះបាទ សម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះចៅក្រុង កម្ពុជា ធិបតី ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញ ព្រះរាជក្រឹត្យ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើតក្រសួងការពារជាតិ និង អគ្គសេនាធិការ នៃ កងយោធពលខេមរភូមិន្ទ

-យោងតាមសំណើរ របស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

សំរេច

មាត្រា ១ : ត្រូវបានបង្កើតនាយកដ្ឋានសំភារៈបច្ចេកទេស ក្រោមការគ្រប់គ្រងបញ្ជាផ្ទាល់ របស់ក្រសួងការពារជាតិ

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នាយឧត្តមសេនាធិការ នៃ កងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី នៃ ក្រសួងពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ដែលចូលជាធរមានចាប់ពី ថ្ងៃឡាយព្រះហស្តលេខា និង ចុះ ហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ ហ៊ុន សែន

* * *

អនុក្រឹត្យលេខ ៥៤ អនក្រ ចុះថ្ងៃទី ១៧ មិថុនា ឆ្នាំ ១៩៩៤
ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃ ព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រនៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- ពិនិត្យសំណូមពរការងារ និង សមត្ថភាពរបស់មន្ត្រីរាជការ
- តាមសំណើរបស់ ឯកឧត្តមអនុរដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

សំរេច

មាត្រា ១ : ត្រូវបានតែងតាំងលោក ត៊ុំ ដារាវុធ ជានាយកអាកាសយានដ្ឋានអន្តរ ជាតិពោធិចិនតុង ។

សំរេច

ប្រការ ១ : ត្រូវបានផ្ទេរសិទ្ធិជូន ឯកឧត្តម ម៉ុម ជឹមហ៊ុយ រដ្ឋលេខាធិការ នៃក្រសួងអប់រំ យុវជន និង កីឡា ជំនួស ឯកឧត្តម ម៉ុក ម៉ារ៉េត រដ្ឋលេខាធិការ គ្រប់គ្រង បរិដ្ឋាន ដែលជាប់អញ្ជើញទៅបំពេញបេសកម្មនៅ ប្រទេសកាណាដា ចំនួន ១០ ថ្ងៃ ចាប់ ពីថ្ងៃទី ១៤ ដល់ ២៤ ខែ មិថុនា ឆ្នាំ ១៩៩៤ ។

ប្រការ ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីរដ្ឋលេខាធិការគ្រប់ ក្រសួង រដ្ឋលេខាធិការដ្ឋាន និង ឯកឧត្តម ដែលមានឈ្មោះក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	ហ៊ុន សែន

* * *

រាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែ មិថុនា ឆ្នាំ ១៩៩៤

សេចក្តីសំរេច លេខ ៦៥ សសរ

ស្តីពីការលុបនិតិវិធី និង បែបបទចាស់នៃការនាំឈើចេញ

រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញនៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រនៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

-យោងសភាពការណ៍យោធា - សន្តិសុខបច្ចុប្បន្ន

-យោងតំរូវការ ជាបន្ទាន់ក្នុងការកសាង និង ពង្រឹងកំលាំងនៃកងយោធពល ខេមរភូមិន្ទ

-បានឃើញសេចក្តីជូនដំណឹងលេខ ១៦៥ សជណ.សរ ចុះថ្ងៃទី ២៩-០១-១៩៩៤ របស់ទីស្តីការគណៈរដ្ឋមន្ត្រីស្តី ពីការបញ្ឈប់ការកាប់ និង ការនាំចេញ ឈើ មូល ឈើអារ នៅដំណាច់ខែ មិនា ឆ្នាំ ១៩៩៤ ។

-បានឃើញសេចក្តីជូនដំណឹងលេខ ៩៣៣ សជណ.សរ ចុះថ្ងៃទី ២០-១២-១៩៩៣ ស្តីពីការប្រគល់ជូនក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ ក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម និង ក្រសួងការបរទេសនិង សហប្រតិបត្តិការអន្តរជាតិ ដោះស្រាយលក់ឈើមូល ។

សំរេច

ប្រការ ១ : លុបនិតិវិធី និង បែបបទនៃការនាំឈើចេញ ដែលបានកំណត់កន្លងមក ។

ប្រការ ២ : កំណត់និតិវិធី និង បែបបទថ្មីនៃការសុំអនុញ្ញាតនាំឈើចេញ មានដូច ខាង ក្រោមនេះ :

- រាល់សំណើ សុំនាំឈើចេញ ត្រូវតែមានការយល់ព្រម អនុញ្ញាតពីនាយករដ្ឋ មន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២ ផ្ទាល់ ។

-ចំពោះឈើដែលបានកាប់រួចហើយ នឹង មានលិខិតអនុញ្ញាតពីក្រសួងមាន សមត្ថកិច្ចកន្លងមក តែពុំទាន់បាននាំចេញ ក្រុមហ៊ុន ឬ អតិថិជន ជាម្ចាស់ឈើ ត្រូវសុំការអនុញ្ញាតជាថ្មីពីនាយករដ្ឋមន្ត្រីទី១ និង ទី ២ តាមរយៈទីស្តីការគណៈ រដ្ឋមន្ត្រី ។

ប្រការ ៣ : សហរដ្ឋមន្ត្រីទទួល បន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួង ការពារជាតិ និង រដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធ ត្រូវអនុវត្តសេចក្តីសំរេចនេះ ចាប់ពី ថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	ហ៊ុន សែន